ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គភាពគាំពារជនរងគ្រោះ
**Victims Support Section**
**Section d'appui aux victimes**

១៩ កក្កដា ២០១០

# សេចក្តីប្រកាសពត៌មាន (ព្រាង)

អង្គភាពគាំពារជនរងគ្រោះសូមប្រកាសជាសាធារណនូវចំនួនស្ថិតិ/ទិន្នន័យទាក់ទងនឹងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណីក្នុងករណីលេខ០០២ ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ និងពត៌មានបន្ថែម ដែលដាក់ជូនមកដោយជនរងគ្រោះនាសម័យខ្មែរក្រហម។

មានអ្នកសុំតាំងខ្លួនចំនួន ៣៩៨៣ ដែលចូលរួម និងកំពុងតែនៅដំណើរការក្នុងករណីលេខ០០២ បន្ទាប់ពីមានមួយចំនួនសុំផ្លាស់ប្តូរទំរង់នៃការចូលរួម និងមានខ្លះសុំដកទំរង់បែបបទខ្លួនវិញ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ ២៩ មក្ករាឆ្នាំ២០១០ នៃការឈប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតរួចមក។

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិចំនួន ៣២០៣ ត្រូវបានបញ្ជូនមក។ រហូតមកដល់ ៣០ មិថុនា ឆ្នាំ២០១០ ដែលជាកាលបរិច្ឆេទផុតកំណត់នៃការឈប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានកំណត់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតរួចមក មានអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋវេណីចំនួន ២១៣៦ បានដាក់ពត៌មានបន្ថែមដើម្បីពង្រឹងដល់ទំរង់បែបបទរបស់ខ្លួនដែលបានដាក់មកពីដំបូង។ បច្ចុប្បន្ន អង្គភាពគាំពារជនរងគ្រោះកំពុងតែពិនិត្យ សង្ខេប និងវិភាគដើម្បីជំរុញឲ្យបានឆាប់រហ័យក្នុងការដាក់បញ្ជូនទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលជាការិយាល័យវិភាគ និងវាយតម្លៃពាក់ព័ន្ធនឹងការសម្រេចឲ្យអ្នកដាក់ទំរង់បែបបទមានសិទ្ធិក្លាយជាភាគីដើមបណ្តឹងរដ្ឋវេណី។

មានជនរងគ្រោះចំនួន ៤១៣៥ នាក់បានដាក់ពាក្យបណ្តឹងមក អ.វ.ត.ក។ បច្ចុប្បន្ន អង្គភាពគាំពារជនរងគ្រោះ នៅតែបន្តទទួល និងចាត់ការសមស្របលើពាក្យបណ្តឹង និងពត៌មានបន្ថែមបន្តទៀត និងបញ្ជូនទៅកាន់ការិយាល័យសហព្រះរាជអាជ្ញាបន្ទាប់ពីពិនិត្យតាមនីតិវិធីរួចមក។

ឆ្លៀតក្នុងឱកាសនេះ អង្គភាពគាំពារជនរងគ្រោះសូមថ្លែងអំណរគុណដល់អង្គភាព និងផ្នែកការងារ

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ផ្សេងទៀតរបស់ អ.វ.ត.ក មេធាវីរដ្ឋប្បវេណី អង្គការអន្តរការី ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការជួយសំរួល និងការធ្វើឲ្យប្រសើរឡើងដល់ការចូលរួមរបស់ជនរងគ្រោះ៕